ព្រះរាជាណាចក្រកម្ពុជា
ជាតិ   សាសនា   ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៦១ ០២០ ១៨៤ ល.ប

ថ្ងៃព្រហស្បតិ៍ ៣កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០

# សេចក្តីបញ្ជាក់

ធនាគារជាតិនៃកម្ពុជា មានតួនាទីបោះផ្សាយរូបិយវត្ថុជាតិ ហើយត្រូវធានាតម្លៃរូបិយវត្ថុទាំងនេះ។ ដូច្នេះ រាល់ការបោះផ្សាយត្រូវមានបដិភាគ ជាទ្រព្យដែលមានតម្លៃ។ ទ្រព្យទាំងនេះរួមមាន រូបិយប័ណ្ណបរទេសនិងមាស ដែលហៅថា "ទុនបម្រុងអន្តរជាតិ" ហើយត្រូវបានរក្សាទុកឱ្យមានសុវត្ថិភាព។ បច្ចុប្បន្ន ទុនបម្រុងអន្តរជាតិរបស់កម្ពុជាគិតជាដុល្លារអាមេរិកមានចំនួន ១៩,៥ ប៊ីលាន គិតត្រឹមចុងខែមិថុនា ឆ្នាំ២០២០។ ធនាគារជាតិនៃកម្ពុជាត្រូវគ្រប់គ្រងដោយប្រុងប្រយ័ត្ន ដើម្បីរក្សាសុវត្ថិភាពទុនបម្រុងទាំងនេះ។ ដូច្នេះ ធនាគារជាតិនៃកម្ពុជាវិនិយោគលើឧបករណ៍ដែលមានស្ថិរភាពខ្ពស់ ដូចជារូបិយប័ណ្ណខ្លាំងនិងមាស។

បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជារក្សាមាស ៣៦,៥ តោន ដែលក្នុងនោះរួមមាន៖

- មាសដែលជាកេរ្តិ៍មរតក តាំងពីមុនសម័យសង្គ្រាម មានចំនួន ១២,៤ តោន ដែលកំពុងរក្សាទុកនៅប្រទេសស្វីស
- មាសចំនួន ១៤,១ តោន កំពុងវិនិយោគនៅធនាគារកណ្តាលអង់គ្លេស និង
- មាសចំនួន ១០ តោន ត្រូវបានរក្សាទុកនៅកម្ពុជា។

ធនាគារជាតិនៃកម្ពុជា មានកាតព្វកិច្ចរាយការណ៍ជាទៀងទាត់នូវរាល់តួលេខនៃទុនបម្រុងអន្តរជាតិនេះ ដល់ស្ថាប័នមានសមត្ថកិច្ចជាតិនិងអន្តរជាតិ។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង, ធនាគារជាតិនៃកម្ពុជា
ទូរសព្ទ ៖ (៨៥៥) ២៣ ៩៨០ ១៨៦
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh